ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ១.ព្រះរាជក្រម


០៩-៩-២០០៤ -ព្រះរាជក្រម នស/រកម/០៩០៤/០០២ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ២០៤៨


### ២.ព្រះរាជក្រឹត្យ


០៩-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៥៤ ស្តីពីការតម្លើងឋានៈស្មើ **រដ្ឋលេខាធិការ** ជូនឯកឧត្តម **សុខ ឈោរ** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាទទួលបន្ទុកផ្នែកនីតិកម្ម ២០៥០

០៩-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៥៥ ស្តីពីការតែងតាំងឯកឧត្តម ចំនួនពីររូបជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាមានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ២០៥១

០៩-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៥៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ឌូ យូរ៉ុន**(DUYURON) សញ្ជាតិដើមចិនកើតនៅខេត្តក្វាងទុងប្រទេសចិន ២០៥២

១៣-៩-២០០៤ -ព្រះរាជក្រឹត្យនស/រកត/០៩០៤/២៥៨ ស្តីពីការតែងតាំង ឯកឧត្តម លោកជំទាវ ចំនួន ១៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេច **ហេង សំរិន** អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៣ ២០៥៣

១៥-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៦២ ស្តីពីការតែងតាំង លោកជំទាវ **ឆាយ ច័ន្ទនឿន** ជាអគ្គនាយក នៃ អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រនៃទីស្តីការគណៈរដ្ឋមន្ត្រី ២០៥៥

១៥-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៦៣ ស្តីពីការតម្លើងឋានន្តរសក្តិជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៥ រូប ២០៥៦


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


០៩-៩-២០០៤ -អនុក្រឹត្យលេខ ៤៩០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២០៥៨

១៣-៩-២០០៤ -អនុក្រឹត្យលេខ ៤៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៦០

## ២.សេចក្តីសំរេច

០៩-៩-២០០៤ -សេចក្តីសំរេចលេខ ៥៥ សសរ ស្តីពីការបង្កើតក្រុមការងារសំរាប់សិក្សាគំរោងប្លង់សាង
សង់អាគារទីស្តីការគណៈរដ្ឋមន្ត្រី ២០៦១

០៩-៩-២០០៤ -សេចក្តីសំរេចលេខ ៥៦ សសរ ស្តីពីការបង្កើតក្រុមការងារសម្របសម្រួល ការដាក់ឱ្យ
ប្រើប្រាស់ម៉ាស៊ីនស្កែនន័រ សំរាប់ការត្រួតពិនិត្យនៅតាមច្រកព្រំដែនអន្តរជាតិ និង
កំពង់ផែអន្តរជាតិ ២០៦៣

១៥-៩-២០០៤ -សេចក្តីសំរេចលេខ ៥៧ សសរ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារទេសចរណ៍
សំរាប់កាត់បន្ថយភាពក្រីក្រ ២០៦៥

## III.ការងារបណ្តាក្រសួង

## ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៥-៩-២០០៤ -ប្រកាសលេខ ១៨៦ ព.ណ បអព.ប្រក ស្តីពីការកែសំរួលនីតិវិធីចេញវិញ្ញាបនប័ត្រ
បញ្ជាក់ប្រភពដើមទំនិញ,វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញតាមជើងយន្តហោះ ២០៦៨

## ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៤-៩-២០០៤ -ប្រកាសលេខ ៦៤៤ ឧរថ.កឧ.ប្រក ស្តីពីការបង្កើតអង្គភាព ចំណុះនាយកដ្ឋានកិច្ចការ
ឧស្សាហកម្ម ២០៧០

## ៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

០៩-៩-២០០៤ -សារាចរណែនាំលេខ ០០១ សរ.សក.ដជ ស្តីពីការអនុវត្តន៍កាតព្វកិច្ចធានារ៉ាប់រងភារៈ
កិច្ចទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង កាតព្វកិច្ចធានារ៉ាប់រង ការ
ដឹកជញ្ជូនអ្នកដំណើរ ២០៧៤

## ៤.ទីស្តីការរដ្ឋមន្ត្រីក្រសួងបរិស្ថាន

១៣-៩-២០០៤ -ប្រកាសលេខ ២០១ ប្រក.បស្ថ ស្តីពីការបង្កើតក្រុមការងារសិលានៃក្រសួងបរិស្ថាន ២០៧៨

## ៥.ទីស្តីការរដ្ឋមន្ត្រីក្រសួង កិច្ចការនារី

១៥-៩-២០០៤ -ប្រកាសលេខ ៥៤៣ កកន.ហជ ស្តីពីការតែងតាំងមន្ត្រីទទួលខុសត្រូវការងារលទ្ធកម្ម
សាធារណៈនៃក្រសួងកិច្ចការនារី ២០៨០

# ព្រះរាជក្រម

នស/រកម/០៩០៤/០០២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័ត យល់ស្របលើទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ:

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា
## ក្នុងអង្គការពាណិជ្ជកម្មពិភពលោក

មាត្រា ១.-

អនុម័តយល់ព្រមលើពិធីសារនៃការចូលរួម របស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដែលបានចុះហត្ថលេខានៅទីក្រុង កែនគុន ប្រទេសម៉ិចស៊ិក នាថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ដូចមានអត្ថបទ ព្រមទាំងឧបសម្ព័ន្ធទាំងស្រុងជូនភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

មាត្រា ៣.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ កញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣ក.០៤០៩.២៥៨

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចម ប្រសិទ្ធ

លេខ: ២០២ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុំ ឌី តាន

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤ / ៧៩៤

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត និសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរតាមចាំបាច់នៃការងារ

## ត្រាស់បង្គាប់

មាត្រា ១: តម្លើងឋានៈស្មើ រដ្ឋលេខាធិការ ជូនឯកឧត្តម ស្វេង ឈោ ជាទីប្រឹក្សាផ្ទាល់របស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកផ្នែកទីតិកម្ម ។

មាត្រា ២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ពាល.០៤០៩.៧៥៥

ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ: ២១២ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាវ ឌី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤/៧៥៥

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមិនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្តម ចំនួនពីររូបដូចខាងក្រោម ជាទីប្រឹក្សាសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

១-ឯកឧត្តម **សុខ ហ៊ាង** ទទួលបន្ទុកការងារសេដ្ឋកិច្ច និងវិនិយោគ

២-ឯកឧត្តម **ឃុន រ៉េង** ទទួលបន្ទុកការងារសេដ្ឋកិច្ច និងវិនិយោគ

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយមានប្រសិទ្ធភាព ព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

រាល-០៤០៩.៧៥៦

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខៈ ២១៣ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាវឌី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤ / ៧៥៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់ជ្រាបសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-**

ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ឌូ យូរ៉ុង ( DU YURONG ) សញ្ជាតិដើមចិន កើតថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៦៧ នៅខេត្តក្វាងតុង ប្រទេសចិន ។

**មាត្រា២.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ កញ្ញា ឆ្នាំ ២០០៤*

គួរប្រោសប្រទាន និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ចាស. ០៤០៩. ៧៥៧

លេខ: ២១១៧-ចណ

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ៩ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សរ៉ាទី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤/២៥៨

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលសម័យប្រជុំលើកទី១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងគណៈកម្មការ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្តទៅលើ សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០០៤ របស់ សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី

## ត្រាស់បង្គាប់

មាត្រា១: តែងតាំង ឯកឧត្តម លោកជំទាវ ចំនួន ១៣ រូប ដូចមានរាយនាមខាងក្រោម ជាទីប្រឹក្សាផ្ទាល់សម្តេច **ហេង សំរិន** អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៣ :

| | | |
|---|---|---|
| ១-ឯកឧត្តម | **ទេង សុត** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២-ឯកឧត្តម | **សារ៉ាម ចំនួនណារិទ្ធ** | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣-ឯកឧត្តម | **អ៊ុំ ឆាយ** | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៤-ឯកឧត្តម | **ឌា ចំនួលីដា** | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៥-ឯកឧត្តម | **ទឹម ស៊ីដា** | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៦-ឯកឧត្តមបណ្ឌិត | **សេង លីម៉េង** | មានឋានៈស្មើ រដ្ឋលេខាធិការ ទទួលបន្ទុកអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៧-ឯកឧត្តម | **ឈាង ម៉ៃត្រី** | មានឋានៈស្មើ រដ្ឋលេខាធិការ ទទួលបន្ទុកកិច្ចការវិនិយោគ |
| ៨-ឯកឧត្តម | **រិត ចាន់ថា** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

៩-ឯកឧត្តម **សុ ផាលណារ៉ូ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

១០-ឯកឧត្តម **តាំង ឈុនធី** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

១១-ឯកឧត្តម **នូ នឹម** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

១២-ឯកឧត្តម **អ៊ុំ វណ្ណារ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

១៣-លោកជំទាវ **ខួន ធួន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា២: ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី **១៣** ខែ កញ្ញា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ការ.០៤០៩.៦៦០

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ: ២១១ - ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៦២

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវ ដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ .-

តែងតាំងលោកជំទាវ ឆាយ ខាន់ឡេន ជា អគ្គនាយក នៃ អគ្គនាយកដ្ឋានរាជកិច្ច និងសេវា-កុំព្យូទ័រ នៃទីស្ដីការគណៈរដ្ឋមន្ត្រី។

មាត្រា២ .-

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៤

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ការ.០៤០៩.២៦៤

លេខ: ២៦៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារ៉ាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៦៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តម្លើងឋានន្តរសក្តិ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៥ រូប :

**ក-តម្លើងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក ជូន :**

ឧត្តមសេនីយ៍ទោ **សំ ចណ្ណថន** អត្តលេខ ០០០២០៥

ខ-គ្រឿងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ជូន :

១- ឧត្តមសេនីយ៍ត្រី ឡេង សីថុន អត្តលេខ ០០០២១៤

២- ឧត្តមសេនីយ៍ត្រី ទេស សោម អត្តលេខ ០០១១៦៧

៣ ឧត្តមសេនីយ៍ត្រី មុំ សីរឿន អត្តលេខ ០០០២០៧

៤- ឧត្តមសេនីយ៍ត្រី ង៉ែង ឆៅរ៉ូ អត្តលេខ ០០០៥២៥

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤*

ត្បូងព្រះបរមនាម និងតាមព្រះរាជក្រាសំបង្គាប់

ប្រមុខរដ្ឋស្តីទី

*៣៧/ស-០៤០៩.២៦៥*

មាត្ញលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ: ៣១៤ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា១ .-**

ត្រូវបានតែងតាំងសមាសភាពថ្នាក់ដឹកនាំ នៃ **អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ** នៃទីស្តីការគណៈរដ្ឋមន្ត្រី ដូចតទៅ :

១- លោក **តុច សុផារ៉ា** ជា អគ្គនាយករង នៃអគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ

២- កញ្ញា **សម សុភាព** ជា ប្រធាននាយកដ្ឋានរាជកិច្ច

៣- លោកស្រី **ហង្ស ទុន្សី** ជា ប្រធាននាយកដ្ឋានសេវាកុំព្យូទ័រ

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាល ខេត្តកំពត

## សម្រេច

**មាត្រា១.** -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ជប៉ុន ចំនួន ០២រូប ដែលបានផ្តល់ថវិកាសំរាប់ជួយកសាង អគារសិក្សា នៅតាមបណ្តាខេត្ត នៃ ព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

១-លោក **គូម៉ា យូអ៊ីជិ** បានជួយសាងសង់អគារសិក្សា ចំនួន ០២ខ្នង មាន ១២បន្ទប់ នៅសាលាបឋមសិក្សា សម្តេចតា ក្នុងឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត ចំណាយអស់ទឹកប្រាក់ ចំនួន ៨៥.៧២៥ ដុល្លារអាមេរិក ។

២-លោកស្រី **មិរីគូ អូកាមូរ៉ា** ប្រធានអង្គការ ASAC ជប៉ុន បានខិតខំផ្តល់ថវិកា ជួយកសាងអគារសិក្សា ចំនួន ជិត ១០០ ខ្នង នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
A106 -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...៥៥...សសរ

# សេចក្តីសំរេច
# ស្តីពី
# ការបង្កើតក្រុមការងារ
# សំរាប់សិក្សាគំរោងបួងសាងសង់អាគារទីស្តីការគណៈរដ្ឋមន្ត្រីថ្មី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់

## សម្រេច

**ប្រការ១ .-**

បង្កើតក្រុមការងារ សំរាប់សិក្សាគំរោងបួងសាងសង់អាគារទីស្តីការគណៈរដ្ឋមន្ត្រីថ្មី ដែលមានសមាសភាពដូចខាងក្រោម÷

១. ឯកឧត្តម **យឹម ឈុលឡា** ទីប្រឹក្សារាជរដ្ឋាភិបាល ប្រធាន

២. ឯកឧត្តម **ឌី យ៉ាន** អនុប្រធាន ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ សមាជិក

៣. ឯកឧត្តម **ម៉ម សុផាន់ណា** អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

៤. ឯកឧត្តម បណ្ឌិតរដ្ឋ **គិច សំណាង** អគ្គលេខាធិការនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សមាជិក

៥. ឯកឧត្តម **អ៊ឹក សុមេត្ត** អគ្គនាយករង អាជ្ញាធរអប្សរា សមាជិក

៦. លោក **ហ៊ុយ ណារ៉ា** អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ សមាជិក

**ប្រការ២ .-**

ក្រុមការងារមានភារកិច្ចទំនាក់ទំនងការងារ និងការសិក្សាគំរោងប្លង់សាងសង់អាគារទីស្តីការគណៈរដ្ឋមន្ត្រីថ្មី ជាមួយភាគីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីលើកជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៦ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារសម្របសម្រួល ការដាក់អោយប្រើប្រាស់ម៉ាស៊ីនស្កេនធំ សំរាប់ការត្រួតពិនិត្យនៅតាមច្រកព្រំដែនអន្តរជាតិ និង កំពង់ផែអន្តរជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ១:** បង្កើតក្រុមការងារសម្របសម្រួលការដាក់អោយប្រើប្រាស់ម៉ាស៊ីនស្កេនធំ សំរាប់ការត្រួតពិនិត្យនៅតាមច្រកព្រំដែនអន្តរជាតិ និង កំពង់ផែអន្តរជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ជា ចាន់ដេត** | នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- លោក **ម៉ក់ ពេជ្ជឫទ្ធិ** | ប្រធាននាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤- លោក **សៀង ឈុនធី** | អនុប្រធានទី១ទីចាត់ការពន្ធ និង រដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២:** ក្រុមការងារនេះមានភារៈកិច្ចដូចតទៅ៖

១- កំណត់ទីតាំងដែលត្រូវដាក់ម៉ាស៊ីនស្កេនន័រអេចល័ត និង ចល័ត សំរាប់ការត្រួតពិនិត្យនៅតាមច្រកព្រំដែនអន្តរជាតិ និង កំពង់ផែអន្តរជាតិ លើកលែងតែកំពង់ផែក្រុងព្រះសីហនុ ។

២- សម្រួលនីតិវិធីនៃការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ ដែលនៅតាមចំណុចដាក់ម៉ាស៊ីនស្កេនន័រ អោយមានភាពរលូន ។

៣- កំណត់ចំនួនម៉ាស៊ីនស្កេនន័រ ដែលត្រូវដាក់នៅតាមទីតាំងនីមួយៗ ។

៤- ចរចារជាមួយភាគីចិនក្នុងការកំណត់តម្លៃ និង ទិញម៉ាស៊ីនស្កេនន័រ ដោយប្រើប្រាស់ជំនួយឥតសំណង និង ឥណទានសម្បទានរបស់រដ្ឋាភិបាលចិន ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ។

៥- ត្រួតពិនិត្យអោយមានប្រសិទ្ធភាព នូវការអនុវត្តន៍ការត្រួតពិនិត្យដោយម៉ាស៊ីនស្កេនន័រនៅតាមច្រកព្រំដែនអន្តរជាតិ និង កំពង់ផែអន្តរជាតិ ។

៦- ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យ និង សម្រេច ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី/រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង សាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៣
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៧ ស.ស.រ

## សេចក្ដីសំរេច

## ស្តីពី

## ការកែសំរួលសមាសភាពក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាហោចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញសេចក្តីសំរេចលេខ ៣៤ ស.ស.រ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ
- បានឃើញសេចក្តីសំរេចលេខ ៤២ ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- តាមការចាំបាច់ចំពោះមុខរបស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ .-**

ត្រូវបានកែសំរួលសមាសភាព ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដែលមានចែងក្នុងប្រការ១ នៃសេចក្តីសំរេចលេខ ៣៤ ស.ស.រ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុម

ការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **វ៉េង សិរីវុឌ្ឍ** | ទេសរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **ឡាយ ប្រហស្ស** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣-ឯកឧត្តម **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានប្រចាំការ |
| ៤-ឯកឧត្តម **សួស គង់** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៥- ឯកឧត្តម **សុន គន្ធះ** | អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៦-ឯកឧត្តម **ជុច ភឿន** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧-ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ | សមាជិក |
| ៨-ឯកឧត្តម **ប៊ុន សម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩-ឯកឧត្តម **ខៀវ មុត** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១០-ឯកឧត្តម **នុត ណារ៉ាង** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១-ឯកឧត្តម **តេង ឡៅ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២-ឯកឧត្តម **វ៉េង សាខុន** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៣-ឯកឧត្តម **ញ៉ឹក ច្រឹង** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៤-ឯកឧត្តម **អ៊ុង តិរុន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៥-ឯកឧត្តម **គីម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៦-ឯកឧត្តម **ថាច់ ដែន** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៧-ឯកឧត្តម **សារ៉ាត់ ខាន់** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៨-ឯកឧត្តម **ខឹម ពិសិដ្ឋ** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៩-ឯកឧត្តម **អ៊ិក សារៈមត្ត** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ២០-ឯកឧត្តម **សូ ម៉ារ៉ា** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធានក្រុមលេខាធិការ និងជាសមាជិក |
| ២១-លោក **ញឹម ខេមរា** | ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី វ៉េង សិរីវុឌ្ឍ | លេខាធិការ |

**ប្រការ២ ._**

ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសំរួលការងារ ។

**ប្រការ៣ ._**

លេខាធិការដ្ឋាន នៃក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ មានទីតាំងនៅទីស្តីការ-គណៈរដ្ឋមន្ត្រី ។

**ប្រការ៤ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥ ._**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត-ក្រុង ពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័ន
- -ដូចប្រការ៥
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
KINGDOM OF CAMBODIA
Nation – Religion – King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
លេខ ១៥៧ ព.ណ.ភ.អ.ក ០៤

ភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៤

## ប្រកាសស្តីពី
## ការកែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ តាមជើងយន្តហោះ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
## និងជាប្រធានអនុគណៈកម្មការសំរបសំរួលពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម .
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម .
- យោងតាមស្មារតីអង្គប្រជុំអនុគណៈកម្មការសំរបសំរួលពាណិជ្ជកម្ម ដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤ ប្រារព្ធធ្វើនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា .
- ដើម្បីសំរួលការងារនាំចេញទំនិញសំលៀកបំពាក់ និង វាយនភ័ណ្ឌ តាមជើងយន្តហោះ

**សំរេច**

**ប្រការ ១ :** ត្រូវបានកែសំរួលបំពេញបន្ថែមប្រការ ១ ចំណុច "ឃ" នៃប្រកាសលេខ ១៥៩ MoC/M2004 ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០០៤ ស្តីពី នីតិវិធីចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ C/O (Certificate of Origin). វិក័យប័ត្រពាណិជ្ជកម្ម C/I (Commercial Invoice). អាជ្ញាប័ណ្ណនាំចេញ E/L (Export License) ចំពោះមុខទំនិញដែលត្រូវដឹកជញ្ជូនតាមជើងយន្តហោះ ដោយត្រូវផ្អែកតាមនិតិវិធីដូចខាងក្រោមនេះ ÷

ក- នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, នាយកដ្ឋានអាស៊ាន និងអង្គការ



Ministry of Commerce, # 20 A & B Preah Norodom Boulevard, Phnom Penh (Kingdom of Cambodia)
Hand Phone : 016 861 616 - 016 988 858 - 016 818 825 - ( 023 ) 725 585 Facsimile : ( 855 ) 23 426 396

អន្តរជាតិ អាចចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O), វិក័យប័ត្រពាណិជ្ជកម្ម (C/I), អាជ្ញាប័ណ្ណនាំចេញ (E/L) តាមជើងយន្តហោះ ជូនក្រុមហ៊ុនដោយផ្អែកតាមវិក័យប័ត្រ (Invoice) និង តារាងបញ្ជាក់ការវេចខ្ចប់ (Packing List) របស់ក្រុមហ៊ុន ។

ខ- មន្ត្រីនាយកដ្ឋានកាំកុងត្រូលត្រូវសហការជាមួយមន្ត្រីគយ និងរដ្ឋាករ ដើម្បីធ្វើការត្រួតពិនិត្យទំនិញដែលនាំចេញតាមជើងយន្តហោះ ដោយផ្ទៀងផ្ទាត់ជាមួយនឹងឯកសារ C/O, C/I, E/L ដែលបានចេញជូនខាងលើ ។

គ- នៅពេលទំនិញបានចេញផុតពីកម្ពុជាហើយ, មន្ត្រីកាំកុងត្រូលត្រូវបញ្ជូនកំណត់ហេតុត្រួតពិនិត្យរួមរបស់ខ្លួនទៅជូននាយកដ្ឋានជំនាញខាងលើ ដើម្បីមានមូលដ្ឋានត្រួតពិនិត្យ-ផ្ទៀងផ្ទាត់ចំពោះលក្ខខ័ណ្ឌបច្ចេកទេសនានាក្នុងការផលិតរបស់ក្រុមហ៊ុន និង ការអនុវត្តនីតិវិធានប្រភពដើមទំនិញ ។

ឃ-ក្រុមហ៊ុននាំចេញត្រូវរួតរះអោយបានទាន់ពេលវេលាដើម្បីផ្ញើរជូននាយកដ្ឋានជំនាញពាក់ព័ន្ធ នូវឯកសារយោងដទៃ ទៀតដើម្បីភ្ជាប់ជាឯកសារផ្ទៀងផ្ទាត់ រួមមាន ÷

- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមជើងយន្តហោះ (Air Waybill )
- កិច្ចសន្យាទិញ-លក់ (Sale Contract)
- មូលប្បទានប័ត្រ សំរាប់សោហ៊ុយរដ្ឋបាល ឬ សំរាប់កំរៃកូតានាំចេញ ឬ កំរៃនាំចេញ

**ប្រការ ២ :** អគ្គាធិការ, អគ្គនាយកបច្ចេកទេស, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ , ប្រធាននាយកដ្ឋានកាំកុងត្រូល នាយិការខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ជ.ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា**

**ចាម_ប្រសិទ្ធ**

**ចម្លងជូន :**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សោ ខេង**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
-ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
-ស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
-អគ្គប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
-ទីចាត់ការគយ និង រដ្ឋាករ
-សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៦៤៤ ឧរ៉ថ.ករ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតអង្គភាពផលិតភាព ចំណុះនាយកដ្ឋានកិច្ចការឧស្សាហកម្ម

**************

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញប្រកាស លេខ១៩៥ បល.ប្រក ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានកិច្ចការឧស្សាហកម្ម

-បានឃើញលិខិតលេខ ៣២០សជណ.ឧស ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-តាមសំណើរបស់ អគ្គនាយកដ្ឋានឧស្សាហកម្ម និង

- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

## <u>សំរេច</u>

<u>ប្រការ១</u>: ត្រូវបានបង្កើតអង្គភាពផលិតភាព បន្ថែមទៅក្នុងរចនាសម្ព័ន្ធរបស់នាយកដ្ឋានកិច្ចការឧស្សាហកម្ម

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣. ៤២៨២៦៣
45 Preah Norodom Boulevard , Khan Daun Penh, Phnom Penh , Phone : 855. 23 . 211141 Fax : 855 23 428263

**តួនាទី:**

អង្គភាពផលិតភាពជាសេនាធិការអោយថ្នាក់ដឹកនាំនាយកដ្ឋានលើការងារគ្រប់គ្រង និង ជំរុញការលើកកំពស់ផលិតភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ភារកិច្ច:**

- បំពេញភារៈកិច្ចនិងអនុវត្តកាតព្វកិច្ចក្នុងនាមជាសមាជិកអង្គការផលិតភាពអាស៊ី
- គ្រប់គ្រង សម្របសំរួល និងជំរុញការលើកកំពស់កំណើនផលិតភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលជាមួយវិស័យឯកជននិងក្រសួងឬស្ថាប័នពាក់ព័ន្ធដើម្បីលើកកំពស់ផលិតភាពការងារនិងសេដ្ឋកិច្ច
-ទំនាក់ទំនងទ្វេភាគី ឬ ពហុភាគីជាមួយអង្គការផលិតភាពជាតិនៃបណ្តាប្រទេសនានា
-រៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ក្នុងទិសដៅអភិវឌ្ឍវិស័យផលិតភាពសំរាប់សេដ្ឋកិច្ច-សង្គម
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងផ្សព្វផ្សាយឯកសារពិតមានផលិតភាព
- សហការ ឬ ផ្តល់សេវាកម្ម ពិគ្រោះយោបល់ និងបណ្តុះបណ្តាលលើផ្នែកផលិតភាព

**ប្រការ២** :អង្គភាពផលិតភាព ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ប្រការ៣** : អង្គភាពផលិតភាពមានរចនាសម្ព័ន្ធដូចតទៅ:

-ផ្នែករដ្ឋបាល : ទទួលបន្ទុកការងាររដ្ឋបាល បុគ្គលិក និងលិខិតបទដ្ឋាននានារបស់អង្គភាព។

-ផ្នែកលើកកំពស់និងជំរុញផលិតភាព: ទទួលបន្ទុកលើកកំពស់និងជំរុញចលនាផលិតភាព

-ផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍: ទទួលការងារស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងផ្សព្វផ្សាយឯកសារពិតមានលើវិស័យផលិតភាព

-ផ្នែកពិគ្រោះយោបល់និងបណ្តុះបណ្តាល: ទទួលផ្តល់សេវាកម្មពិគ្រោះយោបល់ និងបណ្តុះបណ្តាល បច្ចេកទេសបង្កើនផលិតភាព។

**ប្រការ៤**: បទប្បញ្ញត្តិ និង សេចក្តីសំរេចទាំងឡាយណាដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវ

ចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម មានភារៈកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ៦:** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៤

ស៊ុយ សែម

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់នាយកដ្ឋាន
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្ត-ក្រុង
  "ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

តារាងឧបសម្ព័ន្ធទី១ នៃប្រកាសលេខ : ៦៤៤ ក្រ.ក.ឧ
ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤

## អង្គការលេខ អង្គភាពផលិតភាព




បានឃើញ
ភ្នំពេញ,ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០០៤
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ស៊ុយ សែម

បានឃើញ
ភ្នំពេញ,ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៤
អគ្គនាយកឧស្សាហកម្ម

ឌិត - ទីណា

ភ្នំពេញ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ០៤
ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម

កែវ សុវត្ថិ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខៈ ០០១៧៥...សក.ដជ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៧ ឆ្នាំ ២០០៤...

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តន៍កាតព្វកិច្ចធានារ៉ាប់រងភារៈកិច្ចទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ

ដើម្បីធានាអោយកិច្ចដំណើរការអនុវត្តន៍ប្រកាសអន្តរក្រសួងលេខ៦៥៣ប្រក.សហវ.សក.ទច.មជ ចុះថ្ងៃទី ១៦ ខែតុលាឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង ប្រកាសអន្តរក្រសួងលេខ ៦៥៤ ប្រក.សហវ.សក.ទច.មជ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ប្រព្រឹត្តទៅអោយបានល្អប្រសើរ មានតម្លាភាព និង ធានាអភិបាលកិច្ចល្អ ក្រសួងសាធារណការ និង ដឹកជញ្ជូនសូមធ្វើការណែនាំដល់អគ្គនាយកដ្ឋានដឹកជញ្ជូន និង មន្ទីរសាធារណការ និង ដឹកជញ្ជូនគ្រប់ខេត្ត - ក្រុង ទាំងអស់អនុវត្តដូចតទៅ ÷

I- ប្រភេទមធ្យោបាយដឹកជញ្ជូន

ក- យានយន្តជាប់កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន

ប្រភេទយានយន្តដែលត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន សំរាប់គ្រោះថ្នាក់ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមាន ÷

- យានយន្តធ្វើអាជីវកម្មដឹកទំនិញ - ដឹកអ្នកដំណើរ និង ភ្ញៀវទេសចរ .
- យានយន្តគ្រប់ប្រភេទ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន - រោងចក្រ - សហគ្រាស
- យានយន្តរបស់អង្គការក្រៅរដ្ឋាភិបាល - អង្គការអន្តរជាតិ និង សមាគមនានា
- ឧបករណ៍លាយស៊ីម៉ង់ត៍ ដែលធ្វើចលនាផ្លាស់ប្តូរទីកន្លែងដោយម៉ាស៊ីនផ្ទាល់ ឬ អូសដោយក្បាលសណ្តោង
- គ្រឿងចក្រយានយន្ត ដែលប្រើប្រាស់សំរាប់ធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ និង អ្នកដំណើរ ។

ខ- រថយន្តជាប់កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ

ប្រភេទយានយន្តដែលត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរសំរាប់គ្រោះថ្នាក់ ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមាន ៖

- រថយន្តដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ
- រថយន្តដឹកភ្ញៀវទេសចរ
- រថយន្តដឹកសិស្ស
- រថយន្តដឹកកម្មករ- កម្មការិនីរបស់ក្រុមហ៊ុន - រោងចក្រ ឬ សហគ្រាស
- ត្រីចក្រយានយន្តដឹកជញ្ជូនអ្នកដំណើរ

## II- សំណុំឯកសារដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម

រាល់សំណុំឯកសារដែលត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនមានដូចខាងក្រោម ៖

| | |
|---|---|
| ១- ពាក្យសុំមានបិទតែមប្រយ័ត្រឹមត្រូវ | ០១ ច្បាប់ |
| ២- ប័ណ្ណសំគាល់យានយន្តថតចំលង | ០១ ច្បាប់ |
| ៣- វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តច្បាប់ដើម | ០១ ច្បាប់ |
| ៤- ប័ណ្ណបើកបរថតចំលង | ០១ ច្បាប់ |
| ៥- ប័ណ្ណសន្យារ៉ាប់រងថតចំលង | ០១ ច្បាប់ |
| ៦- បង្កាន់ដៃបង់សិទ្ធិ | ០១ ច្បាប់ |

## III- លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន

១- ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនចំពោះយានយន្តដឹកជញ្ជូនទំនិញគ្រប់ប្រភេទ ដែលបានទិញធានារ៉ាប់រងទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង ធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ចំពោះរថយន្តដឹកអ្នកដំណើរ - ភ្ញៀវទេសចរ - សិស្ស - បុគ្គលិក - កម្មករ - កម្មការិនី ។ល។

២- ក្នុងករណីដែលម្ចាស់យានយន្ត ឬ អ្នកបើកបរមិនបានទិញធានារ៉ាប់រង ដូចបានបញ្ជាក់ខាងលើនេះទេ ក្រសួងសាធារណការ និង ដឹកជញ្ជូន អាចចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនអោយប្រើប្រាស់ជាបណ្តោះអាសន្ន ។ ក្រោយរយៈពេល៦០ថ្ងៃនៃការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មរួចមក ម្ចាស់យានយន្ត ឬ អ្នកបើកបរនៅតែមិនព្រមបំពេញកាតព្វកិច្ចធានារ៉ាប់រង ក្រសួងសាធារណការ និង ដឹកជញ្ជូនត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម និងវិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ឬ បញ្ឈប់មិនអោយយានយន្តទាំងនោះធ្វើចរាចរនៅលើផ្លូវសាធារណៈតទៅទៀតឡើយ ។ ឯកសារដកហូតនេះនឹងត្រូវប្រគល់ទៅអោយម្ចាស់យានយន្ត ឬ អ្នកបើកបរវិញ

នៅពេលដែលខ្លួនបានបង្ហាញដល់មន្ត្រីជំនាញមន្ត្រីនៃក្រសួងសាធារណការ និង ដឹកជញ្ជូននូវកាតព្វកិច្ចធានារ៉ាប់រង ដែលខ្លួនបានទិញពីក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកណាមួយ ។

## IV- គ្រប់ខ័ណ្ឌនៃកាតព្វកិច្ចធានារ៉ាប់រង

ក្រុមហ៊ុនធានារ៉ាប់រង មិនទទួលខុសត្រូវចេញសំណងអោយអ្នកដែលត្រូវបានធានារ៉ាប់រងភារៈទទួលខុសត្រូវ យានយន្ត ឬ ធានារ៉ាប់រងតតិយជន និង ធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរក្នុងករណី :

-អ្នកបើកបរគ្មានប័ណ្ណបើកបរស្របច្បាប់ ឬ ប័ណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយានយន្ត ឬ ប័ណ្ណបើកបរហួសសុពលភាព

-អ្នកបើកបរស្ថិតនៅក្នុងភាពស្រវឹងជាក់ស្តែង ហើយមានអត្រាជាតិអាល់កុលចាប់ពី ០,៨០ ក្រាមក្នុងឈាមមួយលីត្រឡើងទៅ ឬ ស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងញៀន ផ្អែកតាមការធ្វើកោសល្យវិច្ឆ័យរបស់មន្ទីរពេទ្យ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុភ្ជាក់ងារត្រួតពិនិត្យរបស់ក្រុមហ៊ុនធានារ៉ាប់រង ឬ នគរបាលចរាចរខេត្ត - ក្រុង

-ការខូចខាតដែលកើតឡើងចំពោះអ្នកដំណើរនៅក្នុងយានយន្ត ដែលជាប់កាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ ហើយម្ចាស់យានយន្ត ឬ អ្នកបើកបរគ្មានការធានារ៉ាប់រង

-នាយកដ្ឋានឧស្សាហកម្ម និង ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានបញ្ជាក់ថា ប័ណ្ណធានារ៉ាប់រងនោះមិនត្រឹមត្រូវ

## V- ការសហការអនុវត្តកាតព្វកិច្ចធានារ៉ាប់រង

មន្ទីរសាធារណការ និង ដឹកជញ្ជូន និង ប៉ូលីសចរាចរគ្រប់ខេត្ត-ក្រុង ត្រូវរួមសហការអនុវត្តការត្រួតពិនិត្យ និងផែនការនូវរាល់ឯកសារដឹកជញ្ជូនដូចជាប័ណ្ណសំគាល់យានយន្ត ប័ណ្ណបើកបរ វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និង ប័ណ្ណសន្យារ៉ាប់រងចំពោះយានយន្តដឹកទំនិញ និង អ្នកដំណើរគ្រប់ប្រភេទនៅតាមចំណតរថយន្តខេត្ត - ក្រុងអោយបានម៉ឺងម៉ាត់ជាប់ជាប្រចាំ ។

ក្នុងករណីយានយន្តមិនមានឯកសារដឹកជញ្ជូនគ្រប់គ្រាន់ និង មិនមានលតាប័ត្រធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង លតាប័ត្រធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរដែលមានបិទនៅលើកញ្ចក់មុខផ្នែកខាងក្នុង មិនត្រូវអនុញ្ញាតអោយចូលចតនៅចំណតរថយន្តឡើយ ។

នគរបាលចរាចរគ្រប់ខេត្ត-ក្រុងត្រូវ ÷

១-ជាកពិន័យ និង ណែនាំដល់ម្ចាស់យានយន្ត និង ប្រតិបត្តិករដឹកជញ្ជូនអោយទៅទិញធានារ៉ាប់រងក្នុងរយៈពេលយ៉ាងយូរ៧ ថ្ងៃ ។

២-ក្នុងករណីមិនបានអនុវត្តតាមការណែនាំខាងលើ ត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន និង វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ។

៣-ក្នុងករណីមិនរាងចាល ត្រូវឃាត់យានយន្តទុកជាបណ្តោះអាសន្នមិនអោយដំណើរការដឹកជញ្ជូនបន្តទៀត រហូតដល់ម្ចាស់យានយន្ត ឬ ប្រតិបត្តិករដឹកជញ្ជូន បានផ្តល់ឯកសារកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬ ធានារ៉ាប់រងតតិយជន និង ឯកសារកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរត្រឹមត្រូវតាមកាលកំណត់ ។

អគ្គនាយកដ្ឋានដឹកជញ្ជូន និង មន្ទីរសាធារណការ និង ដឹកជញ្ជូនគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តតាមខ្លឹមសារសារាចរណែនាំនេះ និង ធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយដល់គ្រប់ក្រុមហ៊ុនដឹកជញ្ជូន ម្ចាស់យានយន្ត និង ប្រតិបត្តិករដឹកជញ្ជូន អោយបានយល់ជ្រួតជ្រាបអំពីយន្តការនៃការអនុវត្តន៍សារាចរណែនាំក្នុងស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធិភាពខ្ពស់ ។

រដ្ឋមន្ត្រី

ស៊ុន ចាន់ថុល

**កន្លែងទទួល**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងទេសចរ
-គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋានដឹកជញ្ជូន
-គ្រប់មន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្ត-ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ: ២០១ ប្រក.បស្ត

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារសិលា នៃក្រសួងបរិស្ថាន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.ករម.០១៩៦.២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧០៤.១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ៣៦០២/០៣ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ០៩១ គ.ជ.ន.ស ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៤ របស់ គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា
- បានឃើញលិខិតលេខ ០៥៨ សណ.បស្ត ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ក្រសួងបរិស្ថាន
- តំរូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារសិលា នៃក្រសួងបរិស្ថាន ដើម្បីទំនាក់ទំនងការងារជាមួយគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងទំនាក់ទំនងការងារសិលាតាមខ្សែបណ្តោយទៅបណ្តាខេត្ត-ក្រុង ។

**ប្រការ ២** : ក្រុមការងារសិលាក្រសួងបរិស្ថាន មានសមាសភាពដូចខាងក្រោម :

១. លោក **យិន សំរាយ** អនុប្រធាននាយកដ្ឋានផែនការ និងកិច្ចការច្បាប់ ប្រធានក្រុម

២.លោក **ទាវ៉ន់ មន្នីនាថ** អនុប្រធាននាយកដ្ឋានវាយតំលៃធនធានធម្មជាតិ និងគ្រប់គ្រងទិន្នន័យ អនុប្រធានក្រុម

៣. លោក **ស្រី ម៉ារ៉ូណា** ប្រធានការិយាល័យសហគមន៍តំបន់ការពារធម្មជាតិ នៃនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ សមាជិក

៤. លោក **ឈី ហួត** អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានផែនការ និងកិច្ចការច្បាប់ សមាជិក

៥. លោក **ម៉ី សេងឈៀង** មន្ត្រីជំនាញ នៃនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ សមាជិក

**ប្រការ ៣** : ភារកិច្ចរបស់ក្រុមការងារសិលាក្រសួងបរិស្ថានមាន :

- កិច្ចសហការការងារជាប្រចាំជាមួយឯកឧត្តមសមាជិកគណៈកម្មាធិការដឹកនាំការងារសិលាក្រសួងបរិស្ថាន និង អគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារសិលា
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ របស់ក្រុមការងារសិលាក្រសួងបរិស្ថាន ដើម្បីដាក់ជូនឯកឧត្តមថ្នាក់ដឹកនាំក្រសួងបរិស្ថានពិនិត្យ និងសំរេច
- គាំទ្របច្ចេកទេសលើការងារបរិស្ថាន ដល់មន្ទីរបរិស្ថានខេត្ត-ក្រុង ការិយាល័យបរិស្ថានស្រុក-ខណ្ឌ និង ក្រុមប្រឹក្សាឃុំ-សង្កាត់
- តាមដានវាយតំលៃ និងផ្ដល់អនុសាសន៍ជូនថ្នាក់ដឹកនាំក្រសួងបរិស្ថាន
- រាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំក្រសួង អំពីសកម្មភាពការងាររបស់ក្រុមការងារសិលាក្រសួងបរិស្ថាន
- អនុវត្តភារកិច្ចផ្សេងៗដើម្បីប្រយោជន៍ការងារក្រសួងបរិស្ថាន ដែលពាក់ព័ន្ធទៅនឹងកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ។

**ប្រការ ៤** : ខុទ្ទកាល័យទេសរដ្ឋមន្ត្រី អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន អង្គភាពពាក់ព័ន្ធ ដូចក្នុងប្រការ២ ត្រូវអនុវត្តប្រកាសនេះប្រកបដោយប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ម៉ុក ម៉ារ៉េត

ចំលងជូន
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង កិច្ចការនារី

លេខ...៥២៣......កកន.ប្រក

# ប្រកាស
## ស្តីពី
## ការតែងតាំងមន្ត្រីទទួលខុសត្រូវការងារលទ្ធកម្ម សាធារណៈនៃក្រសួងកិច្ចការនារី

*******

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី។

-យោងសេចក្តីប្រកាសលេខ៣១៩ សហវប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥ ក្នុងទំព័រលេខ១៧.១៨.១៩.២០

-យោងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៦.សណន.សហវ.លស. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តនីតិវិធាន និងបទបញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ។

## សំរេច

ប្រការ១ : បង្កើតអង្គភាពលទ្ធកម្មមួយមានឈ្មោះថា " អង្គភាពលទ្ធកម្មក្រសួងកិច្ចការនារី " ដែលមានទីតាំងនៅក្នុងក្រសួងកិច្ចការនារី ។

ប្រការ២: អង្គភាពលទ្ធកម្មក្រសួងកិច្ចការនារីមានក្រុមការងារពីរផ្នែក ទទួលខុសត្រូវកិច្ចប្រតិបត្តការគឺ:

ក. អង្គភាពលទ្ធកម្ម (PU)

ខ. គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតំលៃ និងប្រគល់កិច្ចសន្យា (PEAC)

ប្រការ៣ : ចាត់តាំងលោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការជាអ្នកទទួលខុសត្រូវរួមលើអង្គភាពលទ្ធកម្មក្រសួងកិច្ចការនារី ។

ប្រការ៨ : ចាត់តាំងសមាសភាព និងតួនាទីរបស់ "អង្គភាពលទ្ធកម្ម" (PU) :

១. លោកស្រី **មាស សុខុម** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និង ផ្គត់ផ្គង់ ជាប្រធាន

២. លោក **យឹម សាមន** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និង ផ្គត់ផ្គង់ ជាអនុប្រធាន

៣. អ្នកស្រី **ឌុក ម៉ាឡានី** ប្រធានការិយាល័យថវិកា ជាសមាជិក

**អង្គភាពនេះមានតួនាទី :**

ក. រៀបចំឯកសារចាំបាច់ "រួមមានទាំងឯកសារដេញថ្លៃដោយប្រកួតប្រជែង " សំរាប់ចំលងការលទ្ធកម្មណាមួយដោយធ្វើការពិគ្រោះ ឬដោយមានការឧបត្ថម្ភពីអង្គភាពពាក់ពន្ធ័ផ្សេងទៀតនៅក្នុងក្រសួងកិច្ចការនារី ។

ខ.រៀបចំបោះពុម្ពផ្សាយសេចក្តីអញ្ជើញអោយចូលរួមដេញថ្លៃនៅក្នុងសារពត៌មានជាតិ ឬបរទេស និងផ្ញើលិខិតសាកសួរថ្លៃទៅអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ ។

គ. បញ្ជូនឯកសារដេញថ្លៃទៅអោយភាគីដែលចង់បានឯកសារទាំងនោះ ។

ឃ. ទទួលសំណើដេញថ្លៃ ឬតារាងថ្លៃពីអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការដែលចូលរួមព្រម ទាំងធ្វើការពិនិត្យភាពសមស្រែបរបស់សំណើដេញថ្លៃ ។

ង. បញ្ជូនការងារលទ្ធកម្មដែលចាំបាច់ទៅនាយកដ្ឋានបេទ្ធកឬសាធារណៈ ហើយរៀបចំ និងបញ្ជូនទំរង់របាយការណ៍ដេញថ្លៃ ឬទំរង់របាយការណ៍លទ្ធកម្ម ។

ច. ផ្ញើលិខិតរំពីការទទួលសំណើទៅអ្នកដេញថ្លៃឈ្នះ ព្រមទាំងរៀបចំចុះហត្ថលេខាលើកិច្ចសន្យាដែលបានអនុម័តរួច ។

ប្រការ៩ : ចាត់តាំងសមាសភាព និងតួនាទីរបស់ " គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតំលៃ និងប្រគល់កិច្ចសន្យា" (PEAC) :

១. លោកជំទាវ **យឹម ចំរើន** រដ្ឋលេខាធិការ ប្រធាន

២. លោកជំទាវ **សោម គីមសួគ៌** រដ្ឋលេខាធិការ អនុប្រធាន

៣. លោកស្រី **គង់ សំអួន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ សមាជិក

៤. លោក **យឹម សាមន** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ សមាជិក

៥. លោកស្រី **មាស សុខុម** ប្រធានអង្គភាពលទ្ធកម្ម លេខាធិការ

គណៈកម្មាធិការនេះមានតួនាទី :

ទទួលខុសត្រូវក្នុងការកំណត់បុរេលក្ខណៈសម្បត្តិ ការដេញថ្លៃ ការវាយតំលៃលើសំណើដេញថ្លៃ និងសំណើទីប្រឹក្សា ព្រមទាំងផ្តល់អនុសាសន៍ប្រគល់កិច្ចសន្យា ។

ក៑ ម ៑

<u>ប្រការ៦</u> : ប្រកាសទាំងឡាយណាដែលមានន័យផ្ទុយនឹងប្រកាសនេះត្រូវបានចាត់ទុកជានិរាករណ៍។

ប្រការ៧ : សមាសភាពដែលបានចែងក្នុងប្រការ (៣) (៤) (៥) ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

រដ្ឋមន្ត្រី

គាត ឆន់

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- នាយកដ្ឋានលទ្ធកម្មសាធារណៈនៃ សហវ
" ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍"
- គ្រប់នាយកដ្ឋាននៃ ក.ក.ន" ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន" ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ